ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានសិទ្ធិធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង ចំនួន ១ ដែលមានសកម្មភាព ដូចមានឈ្មោះខាងក្រោម៖

| ល.រ No. | លេខបញ្ជី Registration Number | ឈ្មោះក្រុមហ៊ុន Company Name | ឆ្នាំចុះបញ្ជី Year of Registration | អាសយដ្ឋាន Address | លេខទូរស័ព្ទ Telephone |
|---|---|---|---|---|---|
| 1 | 101 | ហ្គូដ យ៉ប មេន ផៅវ័រ អ៊ិនធើណេសិនណាល ឯ.ក<br>GOOD JOB MAN POWER INTERNATIONAL CO.,LTD. | 2018 | ផ្ទះលេខ១១០A ក្រុម៧ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>No.110A, Group7, Phum Russei1, Sangkat Stueng Meanchey3, Khan Meanchey, Phnom Penh. | 012 742 100<br>015 742 100<br>061 448 880 |

បងប្អូនដែលមានបំណងស្វែងរកការងារធ្វើនៅតំបន់រដ្ឋបាលពិសេសហុងកុង អាចពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **www.mlvt.gov.kh** ឬអាចជ្រើសរើសទីភ្នាក់ងារជ្រើសរើសឯកជន និងចុះឈ្មោះស្វែងរកការងារធ្វើនៅតំបន់រដ្ឋបាលពិសេសហុងកុង ដោយផ្ទាល់តាមកម្មវិធីទូរស័ព្ទដៃ "**MLVT Services**" ឬតាមទូបញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាននៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួង ស្ថាប័នផ្សេងៗ ផ្សារទំនើប ហាងកាហ្វេ ម៉ាតធំៗ និងទីប្រជុំជនសំខាន់ៗ នៅក្នុងរាជធានីភ្នំពេញ។ លោកអ្នកក៏អាចស្វែងរកបញ្ជីឈ្មោះ និងឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន និងអាចតាមដានដំណើរការឯកសារចាប់ពីការចុះឈ្មោះស្វែងរកការងារធ្វើនៅតំបន់រដ្ឋបាលពិសេសហុងកុង រហូតដល់ធ្វើមាតុភូមិនិវត្តន៍មកប្រទេសកំណើតវិញដោយខ្លួនឯងផ្ទាល់តាមរយៈតំណភ្ជាប់ **https://tracking.ocwc.co/**។

រាល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយណាដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើនេះ គឺចាត់ទុកថាជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដូច្នេះសូមសាធារណជនរាយការណ៍ជាបន្ទាន់មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈ Hotline លេខ១២៨៦/១២៩៧ លេខទូរស័ព្ទ ០៨៩ ៩៥៧ ៨៨៩ ឬក្រុមតេលេក្រាម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៣៧៥ និងទូរសារ:(០២៣)៨៨៤ ២៧៦

"សម្រាប់ ពលករទេសន្តរប្រវេសន៍" តាមតំណភ្ជាប់ **https://t.me/KhmerMigrantWorker** ឬទំនាក់ទំនងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។

ដើម្បីជៀសវាងការផ្សព្វផ្សាយព័ត៌មានខុស ដែលអាចនាំឱ្យប្រជាពលរដ្ឋរងគ្រោះ ដោយសារការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងការជ្រើសរើស ឬផ្តល់សេវារកការងារឱ្យធ្វើនៅបរទេសដល់ពលករខ្មែរនៅតាមបណ្តាសារព័ត៌មានណាមួយ ជាពិសេសតាមបណ្តាស្ថានីយ៍វិទ្យុត្រូវមានលិខិតអនុញ្ញាតចេញដោយអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អង្គភាពពាក់ព័ន្ធ បណ្តាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន និងសហការអនុវត្ត។

ថ្ងៃ សុក្រ ៩រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២៥